ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

# សេចក្តីប្រកាសព័ត៌មាន

ថ្មីៗនេះមានសារព័ត៌មានមួយចំនួនបានចុះផ្សាយថា " ប្រធានមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទខេត្តកោះកុង យកដីរដ្ឋលក់ " ដែលក្នុងអត្ថបទទាំងនោះបានសង្កត់ធ្ងន់ថា រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទមានបានសើមមាត់សើមកទេដឹងបានជាសម្ងំស្ងាត់ឈឹងដូច្នេះ។

ចំពោះករណីនេះ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ សូមជម្រាបជូនសាធារណជនឱ្យបានជ្រាបថា ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទមិនបានចេញគោលការណ៍អនុញ្ញាតឱ្យធ្វើការលក់ដូរដីរដ្ឋ និងពុំមានការពាក់ព័ន្ធដូចសារព័ត៌មានចុះផ្សាយនោះទេ។ ផ្ទុយទៅវិញ ក្រសួងបានចាត់ក្រុមការងារអធិការកិច្ចចុះធ្វើអធិការកិច្ចលើការងារដឹកនាំ និងគ្រប់គ្រងរបស់មន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទរាជធានី-ខេត្តជាប្រចាំ។ ជាក់ស្តែងក្រោយពីបានចុះធ្វើអធិការកិច្ចនៅមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទខេត្តកោះកុង ក្រសួងបានដាក់ចេញនូវវិធានការចំនួន១៧ ចំណុចឱ្យមន្ទីរធ្វើការអនុវត្ត និងកែលម្អ ហើយក្នុងនោះក៏បានណែនាំឱ្យធ្វើការស្រាវជ្រាវដីចំនួន០៣កន្លែងរបស់ខណ្ឌរដ្ឋបាលព្រៃឈើដើម្បីចាត់វិធានការតាមនីតិវិធីផងដែរតាមរយៈលិខិតលេខ៨៥៦៣ កសក ចុះថ្ងៃទី២៩ ខែសីហា ឆ្នាំ២០១៨ របស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ។ លើសពីនេះក្រសួងក៏បានចាត់ក្រុមការងារចុះធ្វើអធិការកិច្ចលើការគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋរបស់មន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទខេត្តកោះកុងបន្តទៀត។ បច្ចុប្បន្នក្រុមការងារកំពុងបន្តនីតិវិធីធ្វើអធិការកិច្ចក្នុងស្មារតីទទួលខុសត្រូវខ្ពស់បំផុត។ ក្នុងករណីពិតជាមានកំហុសឆ្គង ក្រសួងនឹងចាត់វិធានការស្របតាមច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិលនៃព្រះរាជាណាចក្រកម្ពុជា។

ព័ត៌មានដូចបានបញ្ជាក់ជូនខាងលើ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ សង្ឃឹមយ៉ាងមុតមាំថា បណ្តាញព័ត៌មាននានា និងសាធារណជន មេត្តាជ្រាប និងផ្តល់កិច្ចសហការជាមួយក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ក្នុងការបំពេញភារកិច្ចឱ្យបានល្អប្រសើរ។

ថ្ងៃ សុក្រ ៣ រោច ខែមាឃ ឆ្នាំច សំរឹទ្ធិស័ក ព.ស.២៥៦២
រាជធានីភ្នំពេញ ថ្ងៃទី ២២ ខែ កុម្ភៈ ឆ្នាំ២០១៩

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

អាសយដ្ឋានលេខ ២០០ មហាវិថីព្រះនរោត្តម សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ កម្ពុជា
Nº 200 Preah Norodom Blvd., Sangkat Tonle Basak, Khan Chamkarmon, Phnom Penh, Cambodia.
ទូរស័ព្ទលេខ : (០២៣) ៧២៦ ១២៨ / ៧២៦ ១២៩ ទូរសារលេខ : (៨៥៥) ២៣-២១៧ ៣២០
Phone : (023) 726 128 / 726 129, Fax : (855) 23 - 217 320